# បច្ចុប្បន្នភាពនៃវប្បធម៌គោរពចាស់ទុំរបស់យុវជនខ្មែរ

*ដោយៈ* **លោកស្រីបណ្ឌិត ជា វណ្ណី**
*ប្រធាននាយកដ្ឋានធម្មសាស្ត្រ ចរិយាសាស្ត្រ និងយេនឌ័រ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្ដីផ្ដើម

*ការគោរពចាស់ទុំ គឺជាសីលធម៌ សុជីវធម៌ និងគុណធម៌ ដែលជាគុណតម្លៃនៃជីវិតដ៏ប្រពៃមិនអាចកាត់ថ្លៃបានរបស់យុវជន។*

*ពាក្យ **សីលធម៌ សុជីវធម៌** និង**គុណធម៌** បើតាមវចនានុក្រមសម្ដេចសង្ឃរាជ **ជួន ណាត** ពាក្យ "**សីលធម៌**" គឺជាកិរិយាមារយាទសណ្ដាប់ធ្នាប់ ដំបូន្មានដែលនាំឱ្យចៀសវាងអំពើអាក្រក់ ហើយឱ្យប្រព្រឹត្តតែអំពើល្អ។ **សុជីវធម៌** មានន័យថា ការរស់នៅដោយល្អ គឺចំណេះ សណ្ដាប់ធ្នាប់ ការដឹងប្រមាណគួរសមក្នុងកិច្ចការប្រាស្រ័យជាមួយនឹងអ្នកដទៃ។ ចំណែក **គុណធម៌** គឺធម៌ដែលមានដំណើរចម្រើនសេចក្ដីសុខទុក្ខតាមជាន់តាមថ្នាក់ បានខាងអំពើល្អអាក្រក់ គឺបុណ្យបាបដែលបុគ្គលធ្វើ សេចក្ដីល្អ សេចក្ដីបរិសុទ្ធ សេចក្ដីអាណិត សណ្ដោសប្រណី។*

*ស្របគ្នានេះ បើមនុស្សរស់នៅមានសីលធម៌ សុជីវធម៌ និងគុណធម៌ខ្ពស់ នឹងទទួលបានតម្លៃដោយការគោរពស្រឡាញ់ពីអ្នកដទៃ ពីមនុស្សជុំវិញខ្លួន ព្រមទាំងចេះគោរពចាស់ទុំនោះ នឹងនាំឱ្យសង្គមជាតិមានសេចក្ដីថ្លៃថ្នូរ ព្រោះមានពលរដ្ឋល្អ និងជាពិសេសយុវជនល្អ។*

*យុវជនជាធនធានដ៏មានសក្ដានុពលធំធេង ក្នុងការបង្កើតថ្មី និងការផ្ដល់ដំណោះស្រាយបច្ចេកទេសសម្រាប់គាំទ្រដល់ជីវភាពប្រជាពលរដ្ឋក្នុងអន្តរកាល នៃការវិវត្តបច្ចេកវិទ្យា ដើម្បីឆ្ពោះទៅរកអនាគតមួយកាន់តែប្រសើរ។ ដូច្នេះយុវជនក៏ត្រូវប្រកាន់ខ្ជាប់នូវសីលធម៌ សុជីវធម៌ និងគុណធម៌ និងការគោរពចាស់ទុំដើម្បីលើកកម្ពស់ចំណេះដឹង ជំនាញវិជ្ជាជីវៈ សមត្ថភាព សហគ្រិនភាព ការច្នៃប្រឌិត នវានុវត្តន៍ តាមរយៈការអប់រំ ផ្សព្វផ្សាយ ការចែករំលែកចំណេះដឹង បទពិសោធន៍ និងរបកគំហើញថ្មីៗបច្ចេកវិទ្យាលើគ្រប់វិស័យ។ បច្ចុប្បន្ននេះ ការរីកចម្រើនផ្នែកបច្ចេកវិទ្យាវិទ្យាសាស្ត្រកំពុងវិវត្តយ៉ាងលឿនរហ័ស និងមានការប្រកួតប្រជែងគ្នាច្រើន ដើម្បីដើរឱ្យទាន់ការប្រែប្រួលនៃ*

សកលលោក។ ប៉ុន្តែ ទន្ទឹមនឹងភាពរីកចម្រើននេះ គេក៏មើលឃើញដែរថា សីលធម៌ និងសុជីវធម៌របស់យុវជន ក្នុងការគោរពចាស់ទុំ ពេលខ្លះហាក់ដូចជាមានការធ្លាក់ចុះ ដែលទាមទារឱ្យមានដំណោះស្រាយផ្សេងៗ ដើម្បីចូលរួមស្តារសីលធម៌ សុជីវធម៌ និងគុណធម៌ឡើងវិញ ពោលគឺការអប់រំសីលធម៌ និងសុជីវធម៌នៃយុវជនជាកត្តាសំខាន់ដែលត្រូវយកចិត្តទុកដាក់ពីគ្រប់ភាគីពាក់ព័ន្ធសង្គម។

បច្ចុប្បន្នសីលធម៌ សុជីវធម៌របស់យុវជនហាក់មិនសមស្របនឹងសីលធម៌ និងសុជីវធម៌តាមទំនៀមទម្លាប់ប្រពៃណីខ្មែរ។ តាមទំនៀមទម្លាប់ប្រពៃណីខ្មែរ នៅពេលជួបគ្នាគេតែងលើកដៃសំពះ ជម្រាបសួរ ឬជម្រាបលាគ្នា។ ក្មេងៗតែងគោរពចាស់ព្រឹទ្ធាចារ្យ គោរពគ្រូបង្រៀន ពេលឃើញមនុស្សចាស់ដើរកាត់ ឬចូលវត្តអារាម ក៏តែងតែដោះមួក ក៏ដូចជាការចុះពីលើយានជំនិះ ដើម្បីសម្តែងការគោរព ដែលជាសីលធម៌ និងសុជីវធម៌មានក្នុងសង្គមខ្មែរពីមុនមក។ ផ្ទុយទៅវិញ យុវជនមួយចំនួននាពេលបច្ចុប្បន្នមិនបានអនុវត្តបែបនេះទេ ច្រើនធ្វើតាមវប្បធម៌បរទេស ចាប់ដៃ ងក់ក្បាល ជាជាងលើកដៃជម្រាបសួរ ឬជម្រាបលាជារបៀបខ្មែរ។ ការណ៍នេះ វាបានជះឥទ្ធិពលលើកត្តាសុជីវធម៌ទាំងក្នុងគ្រួសារ ទាំងក្នុងសាលា ទាំងក្នុងកន្លែងធ្វើការ ក៏ដូចជាសង្គមទូទៅ។

យុវជនចូរចាំថា ការគោរពចាស់ទុំ គឺកើតចេញមកពីការមានសីលធម៌ សុជីវធម៌ និងគុណធម៌ ហើយពេលខ្លះក៏គោរពទៅតាមប្រពៃណីទំនៀមទម្លាប់នៃប្រជាជាតិខ្មែរ។ ចំណែក ការគោរពឋានានុក្រមគឺកើតចេញមកពីការចាត់តាំងនៃថ្នាក់ដឹកនាំ។ រីឯការគោរពគំនិតនិងភាពជាអ្នកដឹកនាំ គឺកើតចេញមកពីឧត្តមគតិរបស់បុគ្គលម្នាក់។ បើយើងចង់ឱ្យអ្នកដទៃគោរពនិងផ្តល់តម្លៃដល់យើង តើយើងបានគោរពនិងផ្តល់តម្លៃដល់ខ្លួនឯងនិងអ្នកដទៃហើយឬនៅ?

យុវជនប្រៀបបានទៅនឹងទំពាំងដែលត្រូវស្នងឫស្សី និងមានតួនាទីសំខាន់សម្រាប់អនាគតប្រទេសជាតិ។ ឥរិយាបថរបស់យុវជនចំពោះការគោរពចាស់ទុំ ការងារនិងសង្គម ពិតជាមានសារៈសំខាន់ ដើម្បីជាគំរូនិងជាត្រីវិស័យក្នុងការបង្ហាញនិងតម្រង់ទិសជាបន្តដល់អនាគតរបស់យុវជនជំនាន់ក្រោយៗផង និងសម្រាប់សង្គមជាតិទូទៅផង។ ដូច្នេះ យុវជនគួរចងចាំផងដែរថា ដើម្បីក្លាយជាទំពាំងដ៏ល្អ ជាសសរទ្រូងដ៏រឹងមាំសម្រាប់ប្រទេសនិងសង្គមជាតិ យុវជនគួរប្រកាន់ខ្ជាប់នូវឥរិយាបថគោរពចាស់ទុំ គោរពការងារ និងសង្គម។

កវីក្រមង៉ុយ លោកបានលើកឡើងពីឥរិយាបថក្នុងការចេះគោរពប្រណិប័តន៍ចាស់ទុំថា«**រៀនបទរៀនបាទ កុំកោងហួសខ្នាត កុំភ្លាត់ខុសផ្លូវ កុំភ្លើនភ្លេចម៉ែ កុំប្រែហួសឪ**

***ឃើញចាស់សក់ស្កូវ កុំស្កូវមើលងាយ»***[1]។

យ៉ាងណាមិញ សុភាសិតខ្មែរក៏បានលើកឡើងពីការចេះគោរពនិងឱ្យតម្លៃទៅលើចាស់ទុំផងដែរ ដូចជា ***ដើយស្អក ឱនដាក់គ្រាប់***។ ក្នុងន័យនៃសុភាសិតនេះ ចាស់បុរាណខ្មែរបានទូន្មានកូនចៅជំនាន់ក្រោយត្រូវចេះដាក់ខ្លួន ឱនលំទោន គោរពផ្តល់តម្លៃមនុស្សចាស់ក៏ដូចជាអ្នកដទៃ ដោយមិនប្រើធម៌ប្រមាថ មិនប្រើធម៌អំនួត ដោយត្រូវប្រើធម៌មេត្តាជំនួសវិញ ដែលរមែងមានគេចូលចិត្ត គេគោរពស្រឡាញ់និងផ្តល់តម្លៃពីអ្នកផង។ បន្ថែមពីនេះ គឺយុវជនត្រូវមានឥរិយាបថសុភាពរាបសា ចេះគោរពចាស់ព្រឹទ្ធាចារ្យ ស្គាល់ញាតិមិត្ត អ្នកភូមិផងរបងជាមួយ។ នៅពេលដែលបុគ្គលគ្រប់រូប អាចប្រតិបត្តិមាគ៌ាទាំងនេះបាន បុរាណាចារ្យខ្មែរលោកតែងចាត់ទុកថា ជនទាំងនោះប្រៀបដូចជាកួរស្រូវដែលឱនដាក់គ្រាប់ ហើយគេអាចយកមកប្រើជាប្រយោជន៍បានគ្រប់តម្រូវការ។ ដូចសុភាសិតមួយពោលថា ***ដើយស្អក ឱនដាក់គ្រាប់*** ដែលបានបង្ហាញពីតម្លៃអប់រំយ៉ាងខ្លាំងដល់ការបណ្តុះឱ្យមនុស្សចេះរស់នៅក្នុងសង្គមដោយគ្មានការរើសអើង និងចេះផ្តល់តម្លៃដល់មនុស្សដូចគ្នា ជាពិសេសមនុស្សចាស់ និងរៀមច្បង។

***ចុះមនុស្សចាស់និងរៀមច្បងវិញ ដើម្បីឱ្យយុវជនគោរពនិងផ្តល់តម្លៃ តើគួរត្រូវមានអ្វីនិងគួរធ្វើអ្វីខ្លះ?***

មនុស្សចាស់និងរៀមច្បង គឺជាអ្នកដែលមានគុណបំណាច់ធំធេងណាស់ក្នុងការបន្សល់នូវមរតក ក្នុងបុព្វហេតុជួយអភិវឌ្ឍន៍ខ្លួន និងកសាងក្រុមគ្រួសារក៏ដូចជាសង្គមជាតិ។ មនុស្សចាស់ខ្លះ បានលះបង់សេចក្តីសុខ លះបង់អាយុជីវិតមិនត្រឹមតែដើម្បីគ្រួសារប៉ុណ្ណោះទេ គឺលោកមានការលះបង់សម្រាប់ជាតិមាតុភូមិថែមទៀតផង លះបង់រហូតដល់ទទួលបានសុខសន្តិភាពនាពេលសព្វថ្ងៃនេះ។ យើងចាត់ទុកមនុស្សចាស់ទាំងនោះថាជាឪពុកម្តាយ ជាព្រឹទ្ធាចារ្យ ជារៀមច្បង ដែលយុវជនទាំងអស់គ្នា ត្រូវរៀនសូត្រតាមនូវចំណុចល្អៗទាំងនោះ ទុកជាចំណុចគំរូ និងចៀសវាងនូវចំណុចមិនល្អនិងអសកម្ម។

ការគោរពដឹងគុណដល់គុណូបការៈដែលឪពុកម្តាយ ចាស់ទុំ ព្រឹទ្ធាចារ្យ រៀមច្បងបានបន្សល់ទុក ជាការដឹងគុណមួយដែលមានតម្លៃ មិនអាចកាត់ថ្លៃបាន។ គុណនេះជាគុណធំធេង ដែលក្នុងនាមយើងជាយុវជន

[1] ក្រម ង៉ុយ ***ច្បាប់ល្បើកថ្មី*** ឆ្នាំ១៩២២ ល្បះទី ១០

ជាអ្នកបន្តវេនជំនាន់ក្រោយ គួរតែរៀនសូត្រតាមគំរូវីរភាព គំរូវិជ្ជមាននៃការលះបង់របស់មនុស្សចាស់ៗ មានមនុស្សចាស់ច្រើន ដែលបានលះបង់សេចក្ដីសុខ លះបង់អាយុជីវិតនៅក្នុងបុព្វហេតុគ្រួសារ បុព្វហេតុសង្គមជាតិជាពិសេសនៅពេលប្រទេសមានសង្គ្រាមៗ បច្ចុប្បន្នយើងអាចរស់នៅជួបជុំគ្នា មានឱកាសអភិវឌ្ឍន៍ខ្លួននិងសង្គមជាតិ ក្រោមម្លប់សន្តិភាពក៏ដោយសារតែមនុស្សចាស់បានតស៊ូ លះបង់ និងជួយអភិវឌ្ឍសង្គមមករកភាពសម្បូរសប្បាយ ភាពជួបជុំនៃមហាគ្រួសារនៃប្រជាជនកម្ពុជាផងដែរ ពោលគឺក្រោមម្លប់សន្តិភាព ក្រោមការដឹកនាំដោយសម្ដេចតេជោ **ហ៊ុន សែន** ដែលតំណាងឱ្យមនុស្សចាស់ម្នាក់នៃមនុស្សចាស់ជាច្រើននាក់ៗ

ប៉ុន្តែទន្ទឹមនឹងការទទួលនូវការផ្ដល់តម្លៃពីយុវជន តើមនុស្សចាស់គួរធ្វើខ្លួនរបៀបណា?

ប្រពៃណីនៃការគោរពចាស់ទុំជាទំនៀមទម្លាប់ដ៏ល្អបំផុតរបស់ជនជាតិខ្មែរៗ មនុស្សចាស់មិនថាមនុស្សប្រុស ឬស្រីដែលមានអាយុច្រើនជាងគេ ត្រូវមានតួនាទីកាតព្វកិច្ចជាគំរូដល់យុវជនដូចជា៖

. **ជាអ្នកសម្របសម្រួលជម្លោះ** មិនថារវាងបុគ្គលនិងបុគ្គល រវាងគ្រួសារនិងគ្រួសារ ក៏ដូចជានៅតាមស្ថាប័ននានាគ្រួសារៗ មនុស្សចាស់ត្រូវចេះជួយក្រើនរំលឹកឱ្យសមាជិកទាំងនោះចេះបំពេញតួនាទីរបស់ខ្លួន ដើម្បីខ្លួនឯង ដើម្បីគ្រួសារ និងដើម្បីសង្គមជាតិ ជាពិសេសគឺការចេះដឹងគុណចំពោះដីដូនដូនតា មាតាបិតា គ្រូបាអាចារ្យ ព្រឹទ្ធាចារ្យ និងរៀមច្បងៗ

. **ជាអ្នកសកម្មក្នុងការថែរក្សាប្រវត្តិសាស្ត្រ កេរដំណែលបន្ត ជាអ្នកគ្រប់គ្រងល្អ** គឺមនុស្សត្រូវប្រតិបត្តិតាមច្បាប់ទម្លាប់ ក៏ដូចជាអភិរក្សប្រពៃណីទំនៀមទម្លាប់ ជំនឿសាសនារបស់ក្រុមដោយឈរលើគោលការណ៍គិតប្រយោជន៍រួមៗ

. **ជាអ្នកដើរតួសំខាន់ក្នុងការធ្វើជាគំរូ** មិនថាការអប់រំ ឬការផ្ដល់យោបល់ ទូន្មានប្រៀនប្រដៅនោះទេ គឺត្រូវធ្វើយ៉ាងណាឱ្យយុវជនជំនាន់ក្រោយឱ្យដើរផ្លូវត្រូវកុំភ្លើតភ្លើនក្មេងម៉ែឪ ក្មេងជាតិសាសន៍ខ្លួនជាដើមៗ តួយ៉ាងដូចជានៅក្នុងច្បាប់ល្បើកថ្មីរបស់លោកតា **ក្រម ង៉ុយ** បានលើកឡើង ថា "***កុំភ្លើនភ្លេចខ្លួន ចេះសាសន៍ចិនយួន កុំចោលខ្មែរយើង កុំធ្វើក្រអឺត កុំពើតកុំពើង កុំពាក់ស្បែកជើង ចូលវត្តលោកសង្ឃៗ***[2]

2 ក្រម ង៉ុយ **ច្បាប់ល្បើកថ្មី** ឆ្នាំ១៩២២ ល្បះទី ៣៧

**.ជាអ្នកខិតខំប្រឹងប្រែងក្នុងការពង្រីកចំណេះដឹងនិងព្រឹងសមត្ថភាព** មិនថាជាអ្នកវិនិយោគ ឬអ្នកបម្រើមន្ត្រីរាជការនោះទេ មនុស្សចាស់គួរតែអភិវឌ្ឍសមត្ថភាពខ្លួនឱ្យបានទាន់ទីផ្សារសេរី ក៏ដូចជាដើរឱ្យទាន់សម័យឌីជីថល ដើម្បីជាគំរូដល់យុវជនថាអាយុគ្រាន់តែតួលេខ ចំណែកឯការអភិវឌ្ឍសមត្ថភាព គឺយើងអាចធ្វើបានគ្រប់ៗគ្នាគ្រប់ពេលវេលានិងគ្រប់ទីកន្លែង។

ពេលខ្លះ ឥទ្ធិពលនិងបញ្ហាសង្គមជាច្រើនអាចបង្វែរចំណាប់អារម្មណ៍ឱ្យមនុស្សចាស់មួយចំនួនឱ្យក្លែចកសាងខ្លួនឯងផងដែរ ជាពិសេសទាក់ទងនឹងសមត្ថភាពចំណេះដឹង និងជំនាញពិតប្រាកដ ដែលអាចផ្សារភ្ជាប់ខ្លួនទៅនឹងទីផ្សារការងារ និងអាចផ្សាភ្ជាប់ខ្លួនទៅនឹងការអភិវឌ្ឍសង្គម។ តាមរយៈការងារដែលមនុស្សចាស់កំពុងធ្វើនោះ អាចនឹងក្លាយជាគំរូដល់យុវជន ពោលគឺមនុស្សចាស់មិនត្រូវប្រកាន់ចរិតក្រអឺតក្រទមអាងខ្លួនមានគុណតម្លៃ ហើយជៀលស្តីថាឱ្យក្មេង មើលងាយក្មេង ថាក្មេងមិនដល់ខ្លួនក្មេងមិនកើត និងមិនផ្តល់ឱកាសឱ្យក្មេងជាដើម។

នេះគឺជាគុណតម្លៃខ្មែរដែលមានជាយូរយារណាស់មកហើយ។ ជាតិសាសន៍ណាក៏ដោយ ក៏គេគោរពគុណតម្លៃនិងអត្តសញ្ញាណជាតិរបស់គេដែរ។ ថ្វីដ្បិតតែគុណតម្លៃរបស់បរទេសមួយចំនួនអាចមានចំណុចល្អដែលគួរទទួលយក ប៉ុន្តែក៏មិនគួរយកគុណតម្លៃបរទេសណាមួយមកលុបចោលគុណតម្លៃ និងអត្តសញ្ញាណជាតិរបស់ខ្លួននិងវប្បធម៌ដូនតាខ្មែរដែរ។

ការឱ្យតម្លៃគ្រួសារ និងសង្គមជាតិគឺតែងតែមាននៅក្នុងសន្ដានចិត្តនៃឈាមជ័រខ្មែរជានិច្ច ដែលខុសពីនៅសង្គមបរទេសជឿនលឿនមួយចំនួន គឺពេលដែលមនុស្សចាស់ទៅ មនុស្សចាស់ទាំងនោះលែងមានគ្រួសារនៅក្បែរទៀតហើយ។ មនុស្សចាស់ទាំងនោះត្រូវនៅកណ្តោចកណ្តែង រង់ចាំថ្ងៃស្លាប់នៅក្នុងមជ្ឈមណ្ឌលមើលថែមនុស្សចាស់ គ្មានកូនចៅឬបងប្អូននៅមើលថែជាប្រចាំដូចប្រជាជាតិខ្មែរយើងទេ ដែលយើងអាចនិយាយបានថា សង្គមជឿនលឿនមួយចំនួនបានបាត់បង់នូវអ្វីដែលហៅថាគុណតម្លៃគ្រួសារ ដែលមនុស្សជាតិគ្រប់រូប ជាពិសេសប្រជាជាតិខ្មែរមិនប្រាថ្នាចង់បានឡើយ។

ដោយមើលឃើញពីគុណតម្លៃរបស់ចាស់ទុំ និងដើម្បីជាការតបស្នង យុវជនគួរតែប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំនូវទិវាមនុស្សចាស់ ដើម្បីជាការគោរពដឹងគុណនិងផ្តល់តម្លៃឱ្យស័ក្តិសមនឹងការលះបង់របស់គាត់។ ដើម្បីរក្សាប្រពៃណីល្អមួយនេះ ក្នុងនាមអ្នកបន្តវេនជំនាន់ក្រោយ យុវជនគួររៀបចំកម្មវិធីជួបជុំជាមួយមនុស្សចាស់មានដូចជា ជីដូនជីតា មាតាបិតា អ៊ំពូមីងនិងរៀមច្បងដែលបង្ហាញពីសកម្មភាពនៃការគោរព

ប្រតិបត្តិ ជាការតបស្នងសងគុណ នូវថវិកា
គ្រឿងឧបភោគបរិភោគ ទៅតាមលទ្ធភាព
អាចធ្វើបាន។

ដោយមើលឃើញពីគុណតម្លៃរបស់
មនុស្សចាស់ រាជរដ្ឋាភិបាលនៃកម្ពុជាបាន
ចេញសារាចរ ស្ដីពី **ការរៀបចំទិវាមនុស្ស
ចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ**
នាថ្ងៃទី១ ខែតុលា ឆ្នាំ២០២២[3]។ គុណូបកា
រៈទាំងឡាយ បានបង្ហាញឱ្យយើងឃើញ
យ៉ាងច្បាស់តាមរយៈសកម្មភាព ដោយផ្ទាល់
ដែលមនុស្សចាស់បានធ្វើ ដែលតម្រូវឱ្យយុវ
ជនបង្កើនការយកចិត្តទុកដាក់ និងគាំទ្រតាម
គ្រប់ មធ្យោបាយ ដើម្បីលើកស្ទួយសុខុមាល
ភាពមនុស្សចាស់ឱ្យបានកាន់តែប្រសើរឡើ
ង។ ជាងនេះទៀត យុវជនគួរជួយគាំទ្រដល់
ការបង្កើតសមាគមចាស់ នៅតាមសហគមន៍
មូលដ្ឋាន ឱ្យមានគ្រប់ឃុំ សង្កាត់ ដើម្បីបង្កើន
ស្មារតី សាមគ្គី ជួយគ្នាទៅវិញទៅមករវាង
មនុស្សចាស់ទូទៅនៅកម្ពុជា ជាពិសេសមនុស្ស
ចាស់ជរា ជនពិការនិងទុរគតគ្មានទីពឹង។
ដោយឡែក កាកបាទក្រហមកម្ពុជា ដៃគូ
អភិវឌ្ឍន៍ សប្បុរសជន អង្គការមិនមែនរដ្ឋាភិ
បាលជាតិ និងអន្តរជាតិនានា ក៏បាននិង
កំពុងបន្តបង្កើនសកម្មភាពឧបត្ថម្ភគាំទ្រ
ផ្នែកជំនួយមនុស្សធម៌ ទាំងស្បៀង សម្ភារៈ
ថវិកា និងបច្ចេកទេស សម្រាប់ផ្ដល់សេវា
សុខុមាលភាពរបស់មនុស្សចាស់ ដែលបាន
និងកំពុងជួបប្រទះការលំបាកទាំងផ្នែក
ជីវភាព និងសុខភាពទាំងផ្លូវកាយនិងផ្លូវ
ចិត្ត។ ជាពិសេសនៅតាមទីវត្តអារាម និង
វិហារសាសនាដែលអាចជួយផ្ដល់ជាទីជម្រក
ឬអាហារទៅតាមលទ្ធភាពជាក់ស្ដែង។

សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ នៅ
តាមគ្រឹះស្ថានឧត្តមសិក្សានិងសាលាចំណេះ
ដឹងទូទៅទាំងអស់ បន្តយកចិត្តទុកដាក់ផ្ដល់
ការអប់រំសីលធម៌ ចរិយាធម៌ សុជីវធម៌ គុណ
ធម៌ និងប្រពៃណីទំនៀមទម្លាប់ល្អៗ ដល់
និស្សិត និងសិស្សានុសិស្សគ្រប់រូប ឱ្យចេះ
គោរពចាស់ព្រឹទ្ធាចារ្យ និងការថែទាំមនុស្ស
ចាស់ ដែលជាប្រពៃណីដ៏ល្អរបស់យើង។

ជាងនេះទៀត គ្រប់គ្រួសារនៅតាម
សហគមន៍នីមួយៗ បន្តពង្រឹងប្រកាន់សីលធម៌
ចរិយាធម៌ សុជីវធម៌ គុណធម៌ និងប្រពៃណី
ល្អរបស់ខ្មែរយើង ជាពិសេសត្រូវអប់រំកូន
និងក្មេងជំនាន់ក្រោយឱ្យចេះគោរពដំបូន្មាន
របស់មាតាបិតា ជីដូនជីតា ចាស់ព្រឹទ្ធាចារ្យ
និងរៀមច្បង។

ម៉្យាងទៀត គ្រប់ស្ថានីយវិទ្យុ និង
ទូរទស្សន៍របស់រដ្ឋ និងឯកជន ព្រមទាំងគ្រប់
ទីភ្នាក់ងារព័ត៌មាន គួរជួយបន្ថែមការ
ផ្សព្វផ្សាយឱ្យបានទូលំទូលាយ អំពីស្នាដៃ

---

[3] https://pressocm.gov.kh/archives/76027

និងសមិទ្ធផលនានា ដែលមនុស្សចាស់ បាន បន្សល់ទុក សម្រាប់មនុស្សជំនាន់ក្រោយ ក៏ដូចជាសង្គមជាតិទាំងមូល និងផ្សព្វផ្សាយសកម្មភាពនានា ដែលបង្ហាញអំពីការយកចិត្តទុកដាក់ និងលើកកម្ពស់សុខុមាលភាពមនុស្សចាស់នៅក្នុងសង្គមកម្ពុជាយើង។

រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតគណៈកម្មាធិការជាតិកម្ពុជា ដើម្បីមនុស្សចាស់ ដែលជាយន្តការអនុវត្តនូវគោលនយោបាយសម្រាប់មនុស្សចាស់និងគម្រោងកម្មវិធីគាំទ្រផ្សេងៗក្នុងការជួយលើកកម្ពស់សុខុមាលភាពមនុស្សចាស់នៅតំបន់និងនៅទូទាំងប្រទេស។

នេះបើយើងនិយាយដោយឡែកសម្រាប់វប្បធម៌នៃការគោរពចាស់ទុំនៅកម្ពុជា គឺជាគុណតម្លៃក្នុងសង្គមខ្មែរ តែបើនិយាយជារួមវិញ វប្បធម៌នៃការគោរពចាស់ទុំ ក៏ជាគុណតម្លៃដ៏សំខាន់សម្រាប់សង្គមមនុស្សទូទៅ។ នៅប្រទេសជប៉ុនវិញ គេមានការរៀបចំជាប្រព័ន្ធសង្គមដែលគេហៅថា Senpai និង kōhai គឺជាពាក្យជប៉ុនដែលប្រើដើម្បីពិពណ៌នាអំពីទំនាក់ទំនងអន្តរបុគ្គលតាមឋានានុក្រមក្រៅផ្លូវការដែលមាននៅក្នុងអង្គការ សមាគម ក្លឹប អាជីវកម្ម និងសាលារៀននៅក្នុងប្រទេសជប៉ុន និងការបង្ហាញពីវប្បធម៌ជប៉ុនទូទាំងសកលលោក។ Senpai (先輩) មានន័យថា ថ្នាក់លើ បុគ្គលិកជាន់ខ្ពស់ ឬមនុស្សចាស់ផ្សេងទៀតដែលអ្នកមានទំនាក់ទំនង។ ផ្ទុយទៅវិញ កូហៃ (後輩) គឺជាមនុស្សតូច ឬទាបជាង។ Senpai និង kohai ត្រូវបានកំណត់ដោយអាយុនិងឋានៈដែលមាននៅក្នុងប្រទេសជប៉ុន។ ប្រព័ន្ធនេះជ្រាបចូលទៅក្នុងសង្គមជប៉ុនទំនាក់ទំនង senpai និង kōhai ប្រៀបបាននឹងពាក្យ **គ្រូនិងសិស្ស រៀមច្បងនិងសិស្សប្អូន** ដែលសិស្សប្អូន(យុវជន)ត្រូវគោរពរៀមច្បង (ចាស់ទុំ) ហើយរៀមច្បងត្រូវមើលថែទំនុកបម្រុងសិស្សប្អូន ដែលវប្បធម៌នៃឥរិយាបថនេះ គឺគេមានការបណ្ដុះជាទូទៅតាំងពីថ្នាក់តូចហើយទោះបីជាធំពេញវ័យក្នុងការបំពេញការងារក្នុងសង្គមរៀងៗខ្លួនក៏ដោយក៏ពួកគេនៅតែគោរពគុណតម្លៃនេះជានិច្ច។

ទំនាក់ទំនងនេះមានប្រភពចេញពីការបង្រៀនខុងជឺ ក៏ដូចជាសីលធម៌ និងសីលធម៌ដែលបានមកដល់ប្រទេសជប៉ុនពីប្រទេសចិនបុរាណ ហើយបានរីករាលដាលពាសពេញទិដ្ឋភាពផ្សេងៗនៃទស្សនវិជ្ជារបស់ជប៉ុន។ ទំនាក់ទំនង senpai-kōhai គឺជាឋានានុក្រមបញ្ឈរ (ដូចជាទំនាក់ទំនងឪពុក-កូន) ដែលសង្កត់ធ្ងន់លើការគោរពចំពោះសិទ្ធិអំណាច ខ្សែសង្វាក់នៃបញ្ជានិងសម្រាប់មនុស្សចាស់ ការលុបបំបាត់គ្រប់ទម្រង់នៃ

ការប្រកួតប្រជែងផ្ទៃក្នុង និងការពង្រឹងការរួបរួម។[4]

ដូច្នេះដើម្បីឱ្យយុវជនរក្សាបាននូវការគោរពដឹងគុណ និងប្តេជ្ញាចិត្តចំពោះចាស់ទុំក្នុងការធ្វើជាទំពាំងស្នងឫស្សីដ៏ល្អនោះ គឺសូមឱ្យចាស់ទុំបន្តធ្វើជាគំរូដល់ក្មេង ហើយក្មេងដែលជាយុវជន ឬទំពាំងស្នងឫស្សីនោះ ក៏ត្រូវរក្សាឱ្យបាននូវឥរិយាល្អដែលខ្មែរធ្លាប់មានពីមុនមកដោយៈ

- ទី១ យុវជនខ្លួនឯងត្រូវរៀនពីខ្លួនឯង (ខ្ញុំជាអ្នកណា? ខ្ញុំកំពុងធ្វើអ្វី? ខ្ញុំទៅណា?)

- ទី២ គ្រួសារឬសហគមន៍ ដើម្បីចូលរួមក្នុងការអប់រំខ្លួនឯងជាបណ្តើរៗ ឱ្យស្របទៅតាមអ្វីដែលជាប្រពៃណីទំនៀមទម្លាប់របស់យើង ដែលឪពុកម្តាយបានណែនាំ ឬក៏អ្វីដែលប្រពៃណីទំនៀមទម្លាប់យើងមាន។ ក្នុងនាមជាមនុស្សចាស់ឬក្នុងនាមជាឪពុកម្តាយ ត្រូវធ្វើជាមនុស្សល្អ ត្រូវធ្វើជាគំរូដល់កូនឬដល់យុវជន ជាពិសេសបង្ហាញពួកគេឱ្យឃើញអំពីអ្វីដែលជាសុជីវធម៌ខ្មែរ។ យើងកុំសង្ឃឹមថា កូនៗមានភាពស្មោះត្រង់ឱ្យសោះ ក្នុងខណៈដែលយើងជាមនុស្សចាស់ជាឪពុកម្តាយតែងតែកុហកបោកប្រាស់គ្នាគ្រប់ពេលវេលានោះ។

- ទី៣ ក្នុងនាមជាគ្រូបង្រៀនត្រូវប្រកាន់ទស្សនៈថា គ្រូបង្រៀនគឺជាគំរូដល់សិស្ស និស្សិតរបស់យើង ដូច្នេះគ្រូត្រូវបង្ហាញដល់សិស្ស និស្សិត នូវអ្វីជាគំរូក្នុងផ្នែកសុជីវធម៌ជាគ្រូបង្រៀនដល់ពួកគេ (គ្រូត្រូវសង្គ្រោះសិស្សដោយធម៌៥យ៉ាង៖ គ្រូគប្បីទូន្មានសិស្សឱ្យបានល្អ គ្រូត្រូវញ៉ាំងសិស្សឱ្យខំប្រឹងប្រែងរៀនសូត្រ គ្រូគប្បីបង្ហាត់សិល្បវិជ្ជាឱ្យអស់មិនលាក់ទុក គ្រូតែងលើកតម្កើងសិស្សណាដែលចេះ និងគ្រូតែងតែពន្យល់ណែនាំនូវហេតុផលក៏ដូចជាផលប្រយោជន៍នៃវិជ្ជាប្រាប់ដល់សិស្ស។

ទោះជាយ៉ាងណាក៏ដោយ ការចង់លើកស្ទួយយុវជនឱ្យប្រតិបត្តិសីលធម៌ខ្មែរក្នុងការគោរពចាស់ទុំដ៏ល្អឡើងវិញនោះ ត្រូវតែមានការចូលរួមគ្រប់ផ្នែកទាំងអស់ក្នុងសង្គម ដូចជាយុវជនខ្លួនឯង គ្រួសារ សាលារៀន ផ្នែកសាសនា និងស្ថាប័នរដ្ឋនានា ជាពិសេសយើងគួរមានមានវិធីសាស្ត្រក្នុងការលើកទឹកចិត្តមនុស្ស ជួនកាលយុវជនគាត់អត់ដឹងអីមួយ ឬធ្វើកំហុសធ្ងន់ដោយប្រការណាមួយ។ យើងមិនគួរដាក់ទណ្ឌកម្ម ឬស្តីបន្ទោសដោយខ្វះការពិចារណាភ្លាមទេ គឺយើងគួរសួរខ្លួនឯងថាតើយើងធ្លាប់ប្រាប់ ឬទូន្មានអប់រំពីបញ្ហាដែលគេបានធ្វើខុសធ្ងន់

[4] សូមមើល Japan's senpai and kohai system - Lingualift

ហើយឬនៅ? យើងគួរតែបង្រៀនអប់រំគាត់ ផ្ដល់ឱកាស និងលើកទឹកចិត្តជាមុនសិន ដ្បិតថា មនុស្សយើងបើសិនជាមានការលើកទឹកចិត្តឱ្យគាត់ដើរផ្លូវត្រូវ ហើយបង្ហាញផ្លូវឱ្យគាត់ឃើញ គាត់ក៏នឹងធ្វើតាម តែបើណែនាំហើយមិនតាម ចាំយើងអាចដាក់ទណ្ឌកម្មទៅតាមកម្រិតនៃទោសកំហុស។

កត្តាដែលជំរុញឱ្យសីលធម៌នៃការគោរពចាស់ទុំរបស់យុវជនមានការថយចុះអាចបណ្ដាលមកពីៈ

- **កត្តាយុវជនខ្លួនឯង** មិនស្គាល់ខ្លួនឯង មិនស្ដាប់ដំបូន្មានឪពុកម្ដាយក៏ដូចជាគ្រូបាអាចារ្យ

- **កត្តាគ្រួសារ** កូនៗដែលឪពុកម្ដាយបានបង្កើតមកហើយ ឪពុកម្ដាយនោះមិនប្រាកដថា អាចណែនាំ គ្រប់គ្រង និងតម្រង់ទិសពួកគេឱ្យបានល្អត្រឹមត្រូវ១០០%ទេ។

- **កត្តាគ្រូបង្រៀន** គ្រូមួយចំនួនដែលធ្វើឱ្យសិស្សមិនគោរព មិនឱ្យតម្លៃ (កត្តាទាំងនេះ គ្រូខ្លះចោទលើកត្តាសង្គម មានន័យថាគ្រូមិនបានបំពេញតួនាទីទៅតាមក្រមសីលធម៌វិជ្ជាជីវៈជាគ្រូបង្រៀន)។ សង្គមតែងឱ្យតម្លៃគ្រូថា ជាឪពុកម្ដាយទី២។ តើគ្រូបានបំពេញនូវគោលធម៌របស់ខ្លួនចំពោះសិស្សនិស្សិតរបស់ខ្លួនបានហើយនៅ? គោរពបានតាមក្រមសីលធម៌វិជ្ជាជីវៈជាគ្រូបង្រៀនហើយឬនៅ? មុននឹងយើងវាយតម្លៃអ្នកដទៃ យើងត្រូវវាយតម្លៃខ្លួនយើងជាមុនសិន។ តើក្នុងនាមយើងជាមនុស្សចាស់ ជាគ្រូបង្រៀននេះ យើងបានធ្វើអ្វីខ្លះដែលជាតម្លៃរបស់ខ្លួនឯងសម្រាប់អ្នកដទៃ (កូនចៅ សិស្ស និស្សិត ឬយុវជន) ហើយឬនៅ? បើធ្វើហើយ តើធ្វើក្នុងកម្រិតណា?

- **កត្តាសង្គម** គឺមនុស្សក្នុងសង្គមដែលអាត្មានិយម ដែលខ្វះចិត្តមេត្តា ករុណា ឧបេក្ខា និងមុទិតា សង្គមដែលមានអំពើហិង្សា កំហឹង អំពើអាក្រក់ ការជេរប្រទេចផ្ដាសា សង្គមដែលមានការចរាចរគ្រឿងញៀន គ្រឿងស្រវឹង បារីវេប ដែលមានផលប៉ះពាល់ដល់សុវត្ថិភាពនិងសុខភាពជាដើម។

ការកសាងសង្គមគឺចាប់ផ្ដើមពីការកសាងខ្លួនយើង កសាងគ្រួសារយើង កសាងក្រុម និងស្ថាប័នរបស់យើង ពីព្រោះថាបុគ្គលគ្រប់រូបគឺសុទ្ធតែជាធាតុផ្សំនៃបណ្ដុំសង្គម ឬអាចនិយាយបានថាជាកោសិកានៃសង្គម។ បើធាតុផ្សំនីមួយៗឬកោសិកានៃសង្គមមិនរឹងមាំ សង្គមនោះក៏មិនរឹងមាំដែរ។ ការងារធំគឺចាប់ផ្ដើមពីការងារតូច ការកសាងសង្គមគឺចាប់ផ្ដើមពីការកសាងខ្លួនយើងម្នាក់ៗ។ យើងត្រូវសួរខ្លួនឯងជានិច្ចថា តើយើងបានអភិវឌ្ឍខ្លួនយើងបានរឹងមាំប៉ុនណាហើយ? យើងបានជួយអភិវឌ្ឍគ្រួសារយើងបានប៉ុនណាដែរ? យើងបានជួយអភិវឌ្ឍក្រុមការងារ និងស្ថាប័នការងាររបស់យើងបានប៉ុនណា?

ការបកស្រាយទាំងប៉ុន្មានខាងលើនេះ គឺគ្រាន់តែជាគំនិតមួយចំនួនសម្រាប់ផ្ដល់ឱ្យមនុស្សចាស់និងយុវជនយើងមួយចំនួនយកទៅពិចារណា ក្នុងការអភិវឌ្ឍខ្លួន និងជួយជ្រោមជ្រែង ថែរក្សាសង្គមជាតិខ្មែរ ហើយត្រូវចងចាំជានិច្ចថា គ្មានបរទេសណាស្រឡាញ់ជាតិខ្មែរ ជាងខ្មែរនោះទេ ព្រោះប្រទេសជាតិរបស់គេដែលត្រូវការសេចក្ដីស្រឡាញ់ និងថែរក្សាពីគេដែរ។

យុវជនគួរចងចាំថា ការដែលមានឥរិយាបថល្អឧត្ដុង្គឧត្ដមប្រកបដោយចំណេះដឹងនិងការគោរពចាស់ទុំនៃយុវជននោះយុវជនយើងនឹងក្លាយជាសសរទ្រូងដ៏រឹងមាំរបស់ប្រទេសជាតិយើង៕

## ឯកសារពិគ្រោះ

. ក្រម ង៉ុយ ***ច្បាប់ល្បើកថ្មី*** ឆ្នាំ១៩២២។

. ជា វណ្ណី ***តម្លៃអប់រំនៃការបណ្ដុះធម្មចរិយា*** ឆ្នាំ២០២២។

. ក្រុមប្រឹក្សាជាតិភាសាខ្មែរ ***វចនានុក្រមខ្មែរ*** ការផ្សាយរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃរាជបណ្ឌិត្យសភាកម្ពុជា បោះពុម្ពលើកទី១ ឆ្នាំ២០២២។

. សាន់ នាង ***សុជីវធម៌សម្រាប់បុរសនិងស្ត្រី*** បោះពុម្ពលើកទី១ បណ្ណាគារពេជ្រនិល ឆ្នាំ១៩៦៧

. https://pressocm.gov.kh/archives/76027

. Japan's senpai and kohai system - Lingualift